អាពាហ៍ពិពាហ៍ត្រូវបានគេចាត់ចូលក្នុងវិស័យឧស្សាហកម្មចាប់កំណើតនៅកម្ពុជា

ទិដ្ឋភាពក្នុងពិធីសម្ពោធក្រុមហ៊ុនផ្តល់សេវាអាពាហ៍ពិពាហ៍ (រូបថត អ៊ុយសុង)

រាជធានីភ្នំពេញ : អ្នកស្រី Eileen Lui សហស្ថាបនិកសមាគមវិជ្ជាជីវៈអាពាហ៍ពិពាហ៍ម៉ាឡេស៊ី បានចាត់ទុកអាពាហ៍ពិពាហ៍ចូលក្នុងវិស័យឧស្សាហកម្មដោយហៅថា ឧស្សាហកម្មអាពាហ៍ពិពាហ៍ ។ នេះគឺជាចំណេះដឹងថ្មីមួយទៀតដែលប្រជាពលរដ្ឋកម្ពុជាមិនធ្លាប់បានដឹងថា តើហេតុអ្វីបានជាគេចាត់ទុកអាពាហ៍ពិពាហ៍ចូលទៅក្នុងជំពូកឧស្សាហកម្មបែបនេះទៅវិញ ។

នៅក្នុងពិធីសម្ពោធបើកក្រុមហ៊ុន The Wedding Planners Cambodia ដែលជាក្រុមហ៊ុនផ្តល់សេវាកម្មទទួលរៀបចំអាពាហ៍ពិពាហ៍ ដែលបានធ្វើឡើងនៅភោជនីយដ្ឋាន ១១២ កាលពីថ្ងៃទី៨ សីហាកន្លងមកនេះ អ្នកស្រី Eileen Lui បញ្ជាក់ថា ហេតុដែលគេអាចចាត់ទុកអាពាហ៍ពិពាហ៍ចូលទៅក្នុងវិស័យឧស្សាហកម្មនោះ គឺមកពីពិធីរៀបចំអាពាហ៍ពិពាហ៍កើតឡើងដោយការតម្បាញចូលគ្នានូវផ្នែកជាច្រើនដូចជាការរៀបចំឡើងផ្នែកភ្លេងប្រពៃណី, ម្ហូបអាហារ, ភេសជ្ជៈ, ការដឹកជញ្ជូនបណ្ណាការ, ការបោះពុម្ព, ការថតរូប, ថតវីដេអូ, ការកាត់ត, សំលៀកបំពាក់, អលង្ការ, ថវិកា និងអ្វីៗដែលរួមផ្សំជាច្រើនទៀតពិតទាំងការអញ្ជើញភ្ញៀវ និងការស្វែងរកទីតាំងដ៏សមគួរផងដែរ ។

អ្នកស្រីបញ្ជាក់ថា ក្នុងរដូវអាពាហ៍ពិពាហ៍ មានប្រជាពលរដ្ឋរៀបការប្រហែលពី៥០ទៅ៦០គូក្នុងមួយថ្ងៃ ដែលនោះគឺជាតួលេខមួយដែលអ្នកស្រីរកបានពីការសាកសួរក្នុងចំណោមអ្នកប្រកបរបរសំអាងការជាច្រើនក្នុងប្រទេសកម្ពុជាដែលអ្នកស្រីធ្លាប់បានជួបសាកសួរ ដើម្បីសិក្សាស្វែងយល់អំពីចំនួនអាពាហ៍ពិពាហ៍នៅក្នុងប្រទេសកម្ពុជាដោយផ្ទាល់ខ្លួនប៉ុណ្ណោះ មិនមែនជាតួលេខមួយដែលបានមកពីការសិក្សាស្រាវជ្រាវរបស់ស្ថាប័នណាមួយឡើយ ។ ការរៀបចំរោងអាពាហ៍ពិពាហ៍ជាគំនិតថ្មីទាំងស្រុងមួយក្នុងប្រទេសកម្ពុជា ហើយពិធីអាពាហ៍ពិពាហ៍មានការពេញនិយមណាស់ក្នុងប្រទេសកម្ពុជា។

អ្នកស្រី Eileen Lui ជាសហម្ចាស់ TWP បច្ចុប្បន្ននេះបានស្ថិតនៅក្នុងប្រទេសកម្ពុជា បាននិយាយថា "យើងមិនមានសង្ស័យថា នាពេលបច្ចុប្បន្ននេះទីផ្សារបើកចំហសំរាប់ពួកយើងនោះទេ ។ យើងគ្រាន់តែចង់ឱ្យពួកគេដឹងថា យើងនៅទីនេះហើយជាជំរើសសំរាប់ពួកគេ"។ គាត់បានបន្ថែមទៀតថា "គំនិតរបស់ពួកយើងគឺចង់ឱ្យប្រជាពលរដ្ឋយល់បន្តិចម្តងៗថា យើងមានមធ្យោបាយ និងគំនិតច្នៃប្រឌិតបន្ថែមទៀតសំរាប់ការរៀបចំពិធីមង្គលការ ហើយយើងនៅតែរក្សាប្រពៃណី និងវប្បធម៌របស់ខ្មែរ" ។ ក្រៅពីការច្នៃប្រឌិត និងស្ទីលទាំងអស់ដែលធ្វើឱ្យអាពាហ៍ពិពាហ៍នីមួយៗល្អគ្មាន២ ការជួលអ្នករៀបចំរោងអាពាហ៍ពិពាហ៍ធានាឱ្យអ្នកសំរេចបានតាមគំរោងថវិកា និងពេលវេលាកំណត់ ហើយបានបំបាត់ចោលនូវភាពតានតឹងដែលត្រូវទាក់ទងជាមួយភាគីផ្សេងៗជាច្រើននៅពេលតែមួយ ។

អ្នកស្រី Leticia Hsu សហម្ចាស់ TWP មានប្រសាសន៍ថា "គូស្វាមីភរិយាជាច្រើននាក់ រៀបចំអាពាហ៍ពិពាហ៍ផ្ទាល់ខ្លួនដោយមានជំនួយពីក្រុមគ្រួសាររបស់ពួកគេ ។ បញ្ហាចំបងក្នុងករណីនេះ គឺពួកគេមិនអាចចូលរួមឱ្យបានពេញលេញ និងរីករាយនៅថ្ងៃរៀបអាពាហ៍ពិពាហ៍ទេ ពីព្រោះពួកគេត្រូវរត់ចុះឡើងដើម្បីធានាថា អ្វីៗគ្រប់យ៉ាងដំណើរការយ៉ាងល្អ " ។ គាត់បានបន្តទៀតថា "មានគូស្វាមីភរិយាជាច្រើនណាស់នៅក្នុងប្រទេសម៉ាឡេស៊ី បានស្វែងរកអ្នករៀបចំរោងអាពាហ៍ពិពាហ៍ ពីព្រោះពួកគេចង់ឱ្យខ្លួនឯងហើយនឹងក្រុមគ្រួសាររបស់ពួកគេអាចចូលរួមពិធីអាពាហ៍ពិពាហ៍យ៉ាងពេញលេញ ហើយទម្លាក់ភាពតានតឹងទាំងអស់ទៅឱ្យអ្នករៀបចំរោងអាពាហ៍ពិពាហ៍ " ។

TWP បានចាប់ផ្តើមប្រតិបត្តិការនៅក្នុងប្រទេសកម្ពុជាជាផ្លូវការនៅថ្ងៃទី១៥ ខែមិថុនា ឆ្នាំ២០០៩ ហើយនាំមកជាមួយពួកគេនូវបណ្តាញអ្នកផ្គត់ផ្គង់អន្តរជាតិផ្នែកអាពាហ៍ពិពាហ៍ពីប្រទេសម៉ាឡេស៊ី, សិង្ហបុរី, ឥណ្ឌូណេស៊ី, ហុងកុង, អូស្ត្រាលី និងញូវហ្ស៊ីឡែនផងដែរ ។ អ្នកផ្គត់ផ្គង់ទាំងនេះ គឺជាអ្នករៀបចំរោងអាពាហ៍ពិពាហ៍របស់ The Sothea ដែលស្ថិតក្នុងទីរួមខេត្តសៀមរាប ហើយជាកន្លែងសំរាប់កំសាន្តយ៉ាងប្រណីតជាពិសេសផ្តល់នូវម្ហូបដ៏ពិសេសសំរាប់អ្នកធ្វើដំណើរ ។ ក្នុងរយៈពេលប៉ុន្មានខែខាងមុខនេះ TWP នឹងមានសេវាកម្មជាកញ្ចប់ជាមួយកន្លែងសំរាកកំសាន្តជាន់ខ្ពស់នៅក្នុងតំបន់ដូចជាប្រទេសថៃ, ឡាវ, វៀតណាម និងកោះបាលីផងដែរ ។ TWP ក៏បានផ្តល់ការរៀបចំរោងពិធីជប់លៀង និងការប្រារព្ធពិធីផ្សេងៗសំរាប់ផ្នែកឯកជនផងដែរ ។

អ្នកស្រី Eileen Lui គឺជាស្ថាបនិកក្រុមហ៊ុន Nupts & Such Malaysia (www.Nuptsandsuch.com) សហស្ថាបនិកសមាគមវិជ្ជាជីវៈអាពាហ៍ពិពាហ៍ម៉ាឡេស៊ី (www.awpmalaysia.org) និងជានិពន្ធនាយកនៃទស្សនាវដ្តី Journeysfortwo ដែលជាទស្សនាវដ្តីអាពាហ៍ពិពាហ៍សំរាប់ស្ទីល និងម៉ូតសំលៀកបំពាក់ (www.journeysfortwo.com) ហើយអ្នកស្រីមានបទពិសោធន៍ក្នុងការរៀបចំកម្មវិធី និងព្រឹត្តិការណ៍ផ្សេងៗក្នុងតំបន់ដូចជាប្រទេសម៉ាឡេស៊ី, ប្រទេសកម្ពុជា, ប្រទេសវៀតណាម និងប្រទេសឥណ្ឌូណេស៊ី ។ បច្ចុប្បន្ន អ្នកស្រីស្នាក់នៅប្រទេសកម្ពុជា ហើយគាត់ក៏បានធ្លាក់ក្នុងអន្លង់ស្នេហ៍ជាមួយវប្បធម៌របស់ខ្មែរ ។ ក្រុមហ៊ុន Nupts & Such Malaysia ល្បីល្បាញក្នុងការរៀបចំ រោងអាពាហ៍ពិពាហ៍សំរាប់អតិជនជាអតិថិ នជាច្រើននៅក្នុងប្រទេសម៉ាឡេស៊ីព្រមទាំង នៅបរទេសផងដែរ ។ អ្នកស្រីជឿជាក់ថា អាពាហ៍ពិពាហ៍ គឺជាបទពិសោធន៍តែម្តងគត់ ក្នុងអាគជីវិត ហើយគ្រប់យ៉ាងក្នុងកម្មវិធីគឺ ត្រូវធានាឱ្យបានថា គូស្វាមីភរិយាសប្បាយរីក រាយជាមួយទិវាអាពាហ៍ពិពាហ៍របស់ពួកគេ ។

អ្នកស្រី Leticia Hsu ស្ថាបនិកក្រុមហ៊ុន vents Wizard Malaysia (www.events vizard.net) និងជាសហស្ថាបនិកសមាគមវិជ្ជាជីវៈអាពាហ៍ពិពាហ៍ម៉ាឡេស៊ី (www.awpmalaysia.org) មានបទពិសោធន៍ជាងមួយទសវត្សក្នុងការរៀបចំកម្មវិធី និងព្រឹត្តិការណ៍ជាច្រើន។ អ្នកស្រី Leticia ជាបុគ្គលិកដែលមានទឹកចិត្តខ្ពស់ដើម្បីភាពជោគជ័យ។ ភាពច្នៃប្រឌិត និងតំរូវការភាពជាសហគ្រិន គឺជាចំណូលចិត្តមួយរបស់អតិថិជនក្នុងចំណោមអតិថិជនអាពាហ៍ពិពាហ៍ធំៗរបស់យើងខ្ញុំ ។ អ្នកស្រី Leticia ទទួលបានបរិញ្ញាបត្រផ្នែកវិទ្យាសាស្ត្រពាណិជ្ជកម្មអន្តរជាតិ ជាសមាជិកភាពក្នុងសមាគម និងជាប្រធានប្រតិបត្តិពាណិជ្ជកម្ម ។ ដោយចំណាយពេលវេលាជាមួយក្រុមហ៊ុនអន្តរជាតិ ក្រុមហ៊ុនរៀបចំកម្មវិធីនិងព្រឹត្តិការណ៍ផ្សេង និងបទពិសោធន៍ដ៏ទូលំទូលាយរបស់អ្នកស្រី ព្រមទាំងដោយក្តីស្រលាញ់នូវភាពជោគជ័យ បានធ្វើឱ្យក្រុមហ៊ុន Events Wizard បង្កើតនូវផ្នែកមួយទៀតក្នុងការរៀបចំព្រឹត្តិការណ៍នៅប្រទេសម៉ាឡេស៊ី ។ ដោយក្តីស្រលាញ់ចង់ឱ្យពិធីមង្គលការមានភាពស្រស់ស្អាត បានជំរុញឱ្យអ្នកស្រីព្យាយាមបង្កើតបទពិសោធន៍ដែលគ្មានពីរ សំរាប់គូស្វាមីភរិយានីមួយៗ ។***អ៊ុយសុខ***